**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ:៣៨៤.០០.ប្រ.ក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌជ្រើសរើស
## ឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ សម្រាប់ឆ្នាំ២០១៦

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.តត ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការបំពេញក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ
- យោងតាមសំណូមពរចាំបាច់

## សម្រេច

**ប្រការ ១.–**

ត្រូវបានបើកឲ្យមានការប្រឡងជ្រើសរើសបេក្ខជនចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ សម្រាប់ឆ្នាំ២០១៦ ដើម្បីបំពេញតម្រូវការរបស់ ក្រសួងមហាផ្ទៃ ។

**ប្រការ ២.–**

លក្ខខណ្ឌទូទៅ នៃជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ត្រូវបានកំណត់ដូចខាងក្រោម៖

១-ការប្រឡងជ្រើសរើសឲ្យចូលជានាយនគរបាល ត្រូវជ្រើសរើសចេញពីបេក្ខជនទាំងពីរភេទដែលមានសញ្ញាបត្របរិញ្ញា ឬសញ្ញាបត្រមានតម្លៃស្មើ ឬខ្ពស់ជាងត្រូវមានអាយុយ៉ាងច្រើន ៣០ឆ្នាំ គិតត្រឹមថ្ងៃប្រឡង ។

២-ការប្រឡងជ្រើសរើសឲ្យចូលជានាយរងនគរបាល ត្រូវជ្រើសរើសចេញពីបេក្ខជនទាំងពីរភេទ ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ ឬសញ្ញាបត្រក្រោមមធ្យមសិក្សាទុតិយភូមិ ត្រូវមានអាយុយ៉ាងច្រើន ២៥ឆ្នាំ គិតត្រឹមថ្ងៃប្រឡង។

**ប្រការ៣ ._**

លក្ខខណ្ឌដោយឡែក នៃការប្រឡងជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ នៃប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ/សង្កាត់ និងការិយាល័យជំនាញនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវបានកំណត់ ដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- **ចំពោះក្របខ័ណ្ឌមន្ត្រីការិយាល័យជំនាញ** មានសញ្ញាបត្របរិញ្ញា ឬសញ្ញាបត្រមានតម្លៃស្មើ ឬខ្ពស់ជាង និងមានអាយុយ៉ាងច្រើន ៣០ឆ្នាំ គិតត្រឹមថ្ងៃប្រឡង ឬសញ្ញាបត្របរិញ្ញារង ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ និងមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ២៥ឆ្នាំ គិតត្រឹមថ្ងៃប្រឡង
- មានជីវប្រវត្តិច្បាស់លាស់ និងមិនដែលបានប្រព្រឹត្តិបទល្មើសនានា
- មានសុខភាពល្អ កាយសម្បទាមាំមួន និងគ្មានជំងឺឆ្លង
- មានកម្ពស់ ១.៦៧ម ឡើង សមាមាត្រទៅនឹងទម្ងន់ពី៥៧-៦៧គ.ក្រ ចំពោះបុរស និងមានកម្ពស់ ១.៥៧ម ឡើង មានទម្ងន់ពី៤៧-៥៧គ.ក្រ ចំពោះនារី
- **ចំពោះមន្ត្រីក្របខ័ណ្ឌប៉ុស្តិ៍នគរបាលរដ្ឋបាល** ត្រូវជ្រើសរើសចេញពីក្នុងចំណោមបេក្ខជនដែលមានទីលំនៅក្នុងឃុំ/សង្កាត់សាមី និងមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬក្រោម មធ្យមសិក្សាទុតិយភូមិ ។ ក្នុងករណីគ្មានបេក្ខជនដាក់ពាក្យ ឬដាក់ពាក្យមិនគ្រប់ចំនួន ត្រូវជ្រើសរើសពីក្នុងចំណោមបេក្ខជនដែលមានទីលំនៅក្នុងស្រុក/ក្រុង/ខ័ណ្ឌ ដែលមានព្រំប្រទល់ជាប់គ្នា។

✷**បញ្ជាក់ ៖** ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រ ដែលមានតម្លៃស្មើ ។

**ប្រការ ៤._**

លក្ខខណ្ឌដោយឡែក នៃការប្រឡងជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ នៃនាយកដ្ឋានអង្គរក្ស នាយកដ្ឋាននគរបាលការពារ ត្រូវបានកំណត់ដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរ
- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ ឬសញ្ញាបត្រក្រោមមធ្យមសិក្សាទុតិយភូមិ និងមានអាយុចាប់ពី១៨ឆ្នាំ ដល់ ២៥ឆ្នាំ គិតត្រឹមថ្ងៃប្រឡង
- មានជីវប្រវត្តិច្បាស់លាស់ និងមិនដែលបានប្រព្រឹត្តិបទល្មើសនានា
- មានសុខភាពល្អ កាយសម្បទាមាំមួន និងគ្មានជំងឺឆ្លង
- មានកម្ពស់ ១.៧០ម ឡើង សមាមាត្រទៅនឹងទម្ងន់ពី៦០-៧០គ.ក្រ ចំពោះបុរស និងមានកម្ពស់ ១.៦០ម ឡើង មានទម្ងន់ពី៥០-៦០គ.ក្រ ចំពោះនារី ។

**ប្រការ៥.-**

លក្ខខណ្ឌដោយឡែក នៃការប្រឡងជ្រើសរើសបេក្ខជនជាបុរសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ នៃវរសេនាតូចនគរបាលការពារព្រំដែន និងនគរបាលការពារបេតិកណ្ឌ ត្រូវបានកំណត់ដូចខាងក្រោម៖

- មានសញ្ញាតិខ្មែរ
- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រមានតម្លៃស្មើ ឬសញ្ញាបត្រក្រោមមធ្យមសិក្សាទុតិយភូមិ និងមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ២៥ឆ្នាំ គិតត្រឹមថ្ងៃប្រឡង
- មានជីវប្រវត្តិច្បាស់លាស់ និងមិនដែលបានប្រព្រឹត្តិបទល្មើសនានា
- មានសុខភាពល្អ កាយសម្បទាមាំមួន និងគ្មានជំងឺឆ្លង
- មានកម្ពស់ ១.៦៣ម ឡើង សមាមាត្រទៅនឹងទម្ងន់ពី៥៣-៦៣គ.ក្រ ។

**ប្រការ ៦.-**

លក្ខខណ្ឌ នៃការប្រឡងជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន ក្រុមប្រឹក្សានីតិកម្ម បណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវបានកំណត់ដូចខាងក្រោម ៖

- មានសញ្ញាតិខ្មែរ
- មានសញ្ញាបត្របរិញ្ញា ឬសញ្ញាបត្រមានតម្លៃស្មើ ឬខ្ពស់ជាង និងមានអាយុយ៉ាងច្រើន ៣០ឆ្នាំ គិតត្រឹមថ្ងៃប្រឡង ។ មានសញ្ញាបត្របរិញ្ញារង ឬមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចំពោះបេក្ខជនដែលចេះជំនាញបច្ចេកទេសតាមតម្រូវការចាំបាច់ដោយឡែក នៃអង្គភាពសាមី និងមានអាយុចាប់ពី ១៨ឆ្នាំ ដល់៣០ឆ្នាំ គិតត្រឹមថ្ងៃប្រឡង
- មានជីវប្រវត្តិច្បាស់លាស់ និងមិនដែលបានប្រព្រឹត្តិបទល្មើសនានា
- មានសុខភាពល្អ កាយសម្បទាមាំមួន និងគ្មានជំងឺឆ្លង
- មានកម្ពស់ ១.៦៧ម ឡើង សមាមាត្រទៅនឹងទម្ងន់ពី៥៧-៦៧គ.ក្រ ចំពោះបុរស និងមានកម្ពស់ ១.៥៥ម ឡើង មានទម្ងន់ពី៤៥-៥៥គ.ក្រ ចំពោះនារី ។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៨.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកស្តុភារ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភាននគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ១សភា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ

ក្រសួងមហាផ្ទៃ
គណៈកម្មការកណ្តាលរៀបចំការប្រឡងប្រជែងជ្រើសរើស
ឲ្យបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ :.....០១៣.....សណន

# សេចក្តីណែនាំ
# ស្តីពី
# នីតិវិធីនៃការប្រឡងប្រជែងជ្រើសរើសឲ្យចូលបម្រើការងារ
# នៅក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ឆ្នាំ ២០១៦

អនុវត្តប្រកាសលេខ៣៨០១ ប្រ.ក ចុះថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ ស្តីពីការប្រឡងប្រជែងជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិឆ្នាំ២០១៦ ធានាបាននូវសមធម៌ តម្លាភាព និងមានកិច្ចដំណើរការជាខ្សែសង្វាក់ផ្ទៃបាលមានភាពរលូន គណៈកម្មការកណ្តាលរៀបចំការប្រឡងប្រជែងជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិធ្វើការណែនាំដូចខាងក្រោម:

ក. ដំណាក់កាលផ្សព្វផ្សាយជូនដំណឹង ផ្តល់ ទទួលពាក្យ និងចុះឈ្មោះបេក្ខជន :

១. ការផ្សព្វផ្សាយជូនដំណឹង :

ដើម្បីធានាបានដំណឹងដល់បេក្ខជននៅតាមមូលដ្ឋាន អនុគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសថ្នាក់ក្រសួង និងថ្នាក់រាជធានី ខេត្ត ត្រូវរៀបចំបិទប្រកាសផ្សព្វផ្សាយជូនដំណឹង ស្តីពីការជ្រើសរើសឲ្យបានទូលំទូលាយដល់សាធារណៈជន ។

២. ការផ្តល់ពាក្យជូនបេក្ខជន មានរយៈពេល២០ថ្ងៃ ពីថ្ងៃទី០៥ ដល់ថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ២០១៦ :

នៅពេលមានបេក្ខជនមកទំនាក់ទំនងទទួលសំណុំបែបបទពាក្យសុំចូលបម្រើការងារ អនុគណៈ កម្មការ រៀបចំការប្រឡងប្រជែងជ្រើសរើសរបស់អង្គភាពសាមី ត្រូវប្រកាន់ខ្ជាប់នូវចំណុចសំខាន់ៗមួយចំនួនដូចតទៅ :

- ជាបឋមត្រូវពិនិត្យកាយសម្បទារបស់បេក្ខជនដែលមកទំនាក់ទំនងសុំពាក្យ តើគ្រប់លក្ខណសម្បត្តិដែរឬទេ? ដូចជា ភ្នែក ត្រចៀក ដៃ ជើង ឬកិនកាត ស្លាកស្នាមផ្សេងៗទៀត ។ បន្ទាប់ពីពិនិត្យឃើញគ្រប់លក្ខណសម្បត្តិហើយ ទើបដំណើរការវាស់កម្ពស់ ថ្លឹងទម្ងន់ ព្រមទាំងសាកសួរព័ត៌មានអំពីកំរិតសញ្ញាបត្រ អាយុ ទីលំនៅ អចិន្ត្រៃយ៍...។ ក្រោយពេលពិនិត្យ និងសាកសួរព័ត៌មានរួចរាល់ហើយ ឃើញថាមានលក្ខណសម្បត្តិស្របតាមលក្ខខណ្ឌដែលក្រសួងបានកំណត់ ទើបអនុញ្ញាតផ្តល់ពាក្យ

- ណែនាំបេក្ខជនបំពេញសំណុំបែបបទឲ្យបានត្រឹមត្រូវគ្រប់គ្រាន់នូវព័ត៌មានផ្ទាល់ក្នុងសំណុំលិខិតពាក្យសុំចូល ព្រមទាំងប្រាប់បេក្ខជនឲ្យបានច្បាស់លាស់អំពីកាលបរិច្ឆេទថ្ងៃចាប់ផ្តើមទទួលពាក្យ និងថ្ងៃឈប់ទទួលពាក្យ

៣.ទីកន្លែងផ្តល់ពាក្យ និងចុះឈ្មោះ :

- នៅថ្នាក់កណ្តាល : ការផ្តល់ ទទួលពាក្យ និងចុះឈ្មោះបេក្ខជនធ្វើនៅទីតាំងសាលប្រជុំនាយកដ្ឋានបុគ្គលិក
- នៅថ្នាក់រាជធានី ខេត្ត : ការផ្តល់ ទទួលពាក្យ និងចុះឈ្មោះបេក្ខជនធ្វើនៅទីតាំងស្នងការដ្ឋាននគរបាលរាជធានី ខេត្តសាមី ។

៤. ការទទួលពាក្យបេក្ខជន និងការរៀបចំបញ្ជីឈ្មោះ មានរយៈពេល១៥ថ្ងៃ ពីថ្ងៃទី២៦ ខែ កក្កដា ដល់ថ្ងៃទី០៩ ខែ សីហា ឆ្នាំ២០១៦ :

នៅពេលដែលបេក្ខជនយកពាក្យមកដាក់ អនុគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើស របស់ថ្នាក់ក្រសួង និងរាជធានី ខេត្តត្រូវ :

- ការទទួលពាក្យៈ ត្រូវពិនិត្យមើលបែបបទពាក្យសុំចូលបម្រើការងាររបស់បេក្ខជនឲ្យបានគ្រប់ជ្រុងជ្រោយ ក្នុងករណីពិនិត្យឃើញមានការខ្វះចន្លោះនូវព័ត៌មានណាមួយ ឬមានការកោសលុបច្រើនមិនត្រូវទទួលយក ហើយត្រូវណែនាំសរសេរឡើងវិញឲ្យបានត្រឹមត្រូវ

- ការរៀបចំបញ្ជីឈ្មោះ : នៅពេលពិនិត្យឃើញសំណុំបែបបទរបស់បេក្ខជនបំពេញបានត្រឹមត្រូវ ទើបសម្រេចចុះឈ្មោះបេក្ខជននោះចូលក្នុងបញ្ជីរាយនាមបេក្ខភាពដែលត្រូវអនុញ្ញាតចូលរួមប្រឡងប្រជែងទៅតាមកម្រិតសញ្ញាបត្រ និងឯកទេសនីមួយៗ តាមសេចក្តីជូនដំណឹងរបស់អនុគណៈកម្មការ ដោយហែកបង្កាន់ដៃសុំចុះឈ្មោះមួយកំណាត់ជូនបេក្ខជនក្សោទុកបញ្ជាក់ថា ខ្លួនបានដាក់ពាក្យរួចហើយ និងសម្រាប់យកទៅបង្ហាញជូនក្រុមអនុរក្សនៅពេលចូលបន្ទប់ប្រឡង ។ ដោយឡែកនៅតាមរាជធានី ខេត្តត្រូវរៀបចំបញ្ជីតាមឯកទេស បើមន្ត្រីប៉ុស្តិ៍ត្រូវធ្វើបញ្ជីទៅតាមប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ ចំណុះក្រុង ស្រុក ខណ្ឌនីមួយៗ ដើម្បីងាយស្រួលក្នុងកិច្ចដំណើរការប្រឡង ។

- នៅពេលផុតកំណត់ថ្ងៃទទួលពាក្យអនុគណៈកម្មការនៅថ្នាក់ក្រសួង និងរាជធានី ខេត្ត ដែលមានក្រុមការងារធ្វើសេនាធិការ ត្រូវដំឡើងបញ្ជីរាយនាមបេក្ខជន ដែលបានមកដាក់ពាក្យចំនួន៥ ច្បាប់ និងបញ្ជីបេក្ខជនតាមបន្ទប់ប្រឡងចំនួន៥ ច្បាប់ (មានគំរូតារាងជូនភ្ជាប់) រួចផ្ញើមកគណៈកម្មការកណ្តាលរៀបចំការប្រឡងប្រជែងជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ដែលមានទីតាំងនៅនាយកដ្ឋានបុគ្គលិកក្រសួងមហាផ្ទៃ ចំនួន២ ច្បាប់ ។

ខ.ដំណាក់កាលរៀបចំវិញ្ញាសា :

អនុគណៈកម្មការរៀបចំវិញ្ញាសាត្រូវរៀបចំវិញ្ញាសាប្រឡង ដោយកំណត់មុខវិជ្ជាទៅតាមកម្រិតសញ្ញាបត្រ និងជំនាញឯកទេសរបស់បេក្ខជន មានជាអាទិ៍ :

ខ-១ថ្នាក់កណ្តាល :

+ជំនាញឯកទេសនានា ដូចជា : ព័ត៌មានវិទ្យា,ច្បាប់,ស្ថាបត្យកម្ម,សុខាភិបាល,ភាសាបរទេស...

+ជំនាញនគរបាលការពារ និងអង្គរក្ស

+ជំនាញនគរបាលការពារព្រំដែនទឹក និងការពារបេតិកភណ្ឌ

ខ-២ថ្នាក់រាជធានី ខេត្ត :

+ការិយាល័យជំនាញ

+ប៉ុស្តិ៍នគរបាលរដ្ឋបាល

+នគរបាលការពារព្រំដែនគោក

គ. ដំណាក់កាលប្រឡងប្រជែង :

១. មុនពេលប្រឡងប្រជែង :

- អនុគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសនៅថ្នាក់ក្រសួង និងរាជធានី ខេត្ត ត្រូវរៀបចំបន្ទប់ប្រឡង មានជាអាទិ៍ : តុ កៅអី ក្តារខៀន ដីស សម្ភារចាំបាច់ និងកម្លាំងរក្សាសន្តិសុខ ភ្នាក់ងារសុខាភិបាលសម្រាប់បម្រើការងារប្រឡង ហើយបន្ទប់ប្រឡងកំណត់ត្រឹមចំនួន២៥ នាក់

- ត្រួតពិនិត្យអំពីស្ថានភាពទូទៅ នៃបន្ទប់ប្រឡង ។ បន្ទាប់មកទៀត បិទបញ្ជីឈ្មោះបេក្ខជន និងបទប្បញ្ញត្តិនៅមុខបន្ទប់ប្រឡង

- នៅមុនម៉ោងប្រឡង១៥នាទី ត្រូវប្រមូលផ្តុំបេក្ខជនតម្រង់ជួរនៅមុខបន្ទប់ប្រឡង រួចហើយក្រុមអនុរក្សផ្តើមហៅឈ្មោះបេក្ខជនក្នុងបញ្ជីឈ្មោះឲ្យចូលបន្ទប់ប្រឡង ក្រោមការត្រួតពិនិត្យផ្ទៀងផ្ទាត់ពីក្រុមអនុរក្សដែលកាន់បង្កាន់ដៃមានបិទរូបថតបេក្ខជន ។ ក្នុងករណីឃើញសំណៅឯកសារផ្សេងៗ ទូរស័ព្ទ ឬឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទដែលអាចផ្ទុកឯកសារបានត្រូវដកហូតរក្សាទុកបណ្តោះអាសន្ន

- នៅពេលបេក្ខជនចូលអង្គុយតាមតុរៀងៗខ្លួនរួចហើយ ក្រុមអនុរក្សចាប់ផ្តើមចែកសន្លឹកកិច្ចការ និងណែនាំដល់បេក្ខជនបំពេញឲ្យបានត្រឹមត្រូវលើក្បាលសន្លឹកកិច្ចការដោយប៊ិចពណ៌ខៀវ ព្រមទាំងណែនាំអំពីបទប្បញ្ញត្តិ នៃការប្រឡង និងចុះបញ្ជីវត្តមាន

- ប្រកាសឲ្យបេក្ខជនដឹងពីការប្រើប្រាស់ជួងជាសញ្ញា **ជួងទី១**បេក្ខជនត្រូវចូលបន្ទប់ប្រឡងដើម្បីបំពេញសន្លឹកកិច្ចការប្រឡង **ជួងទី២**ចាប់ផ្តើមវិញ្ញាសា **ជួងទី៣**រំលឹកបេក្ខជនថានៅសល់៥នាទីទៀតដល់ម៉ោងប្រមូលសន្លឹកកិច្ចការ **ជួងទី៤**បេក្ខជនត្រូវប្រគល់សន្លឹកកិច្ចការឲ្យក្រុមអនុរក្ស ។

**២. រៀបចំមណ្ឌលប្រឡង :**

- មណ្ឌលប្រឡងត្រូវរៀបចំនៅតាមរាជធានី ខេត្តនីមួយៗ

- ស្នងការនគរបាលរាជធានី ខេត្តជាប្រធានមណ្ឌល

- ប្រធានអនុគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសថ្នាក់ក្រសួង និងរាជធានី ខេត្តនីមួយៗ ត្រូវចេញសេចក្តីសម្រេចបង្កើតក្រុមការងារ និងក្រុមអនុរក្ស សម្រាប់ការប្រឡងរបស់ខ្លួន ហើយចម្លងជូនមកគណៈកម្មការកណ្តាលរៀបចំការប្រឡងប្រជែងជ្រើសរើស(ដូចមានគំរូជូនភ្ជាប់)

- មុនពេលប្រឡងប្រធានមណ្ឌលនីមួយៗ ត្រូវមានការប្រជុំណែនាំក្រុមការងារអំពីនីតិវិធីនៃការប្រឡងឲ្យស៊ីជម្រៅទូលំទូលាយ ដើម្បីមានដំណើរការរលូន និងប្រសិទ្ធភាព ។

**៣. ពេលបេក្ខជនដំណើរការវិញ្ញាសាសរសេរ :**

- អនុគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសនៅថ្នាក់ក្រសួង និងថ្នាក់រាជធានី ខេត្ត ត្រូវបើកស្រោមប្រធានវិញ្ញាសានៅចំពោះមុខប្រធានមណ្ឌល អនុរក្ស និងតំណាងបេក្ខជនក្នុងបន្ទប់ចំនួន២នាក់ ដើម្បីពិនិត្យស្រោមប្រធានវិញ្ញាសា បើឃើញថាត្រឹមត្រូវ គ្មានស្នាមរហែកទើបកាត់ស្រោមប្រធានវិញ្ញាសា

- នៅពេលបានប្រធានវិញ្ញាសាក្រុមអនុរក្ស ត្រូវសរសេរនៅលើក្តារខៀន ហើយត្រូវមានការសរសេរបញ្ជាក់ (ថេរវេលាប្រឡងចំនួន..................) ។ នៅពេលបេក្ខជនចាប់ផ្តើមសរសេរកិច្ចការមន្ត្រីអនុរក្សម្នាក់នៅពីខាងមុខបេក្ខជន មន្ត្រីម្នាក់ទៀតនៅពីខាងក្រោយ ដើម្បីពិនិត្យសកម្មភាពបេក្ខជន និងធានាឲ្យការប្រឡងប្រព្រឹត្តទៅប្រកបដោយស្ថានភាពល្អប្រសើរ ។

**៤. ពេលចប់ម៉ោងប្រឡង :**

- នៅពេលជួងទី៤បន្លឺឡើងបេក្ខជនត្រូវប្រគល់សន្លឹកកិច្ចការរបស់ខ្លួនជូនក្រុមអនុរក្ស ដើម្បីផ្ទៀងផ្ទាត់ជាមួយបញ្ជីវត្តមានឲ្យបានគ្រប់ចំនួន

- នៅពេលប្រមូលសន្លឹកកិច្ចការបានគ្រប់ចំនួនហើយ ក្រុមអនុរក្សត្រូវចុះហត្ថលេខាលើសន្លឹកកិច្ចការរបស់បេក្ខជន រួចរៀបចំវេចខ្ចប់ឲ្យបានត្រឹមត្រូវប្រគល់ជូនអនុគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសនៅថ្នាក់ក្រសួង និងថ្នាក់រាជធានី ខេត្ត ដើម្បីរក្សាទុកប្រគល់ជូនគណៈកម្មការកណ្តាលរៀបចំការប្រឡងប្រជែងជ្រើសរើសចាត់ចែងតាមនីតិវិធីកំណែ ដែលមានទីតាំងនៅនាយកដ្ឋានបុគ្គលិក ក្រសួងមហាផ្ទៃ ។

ឃ. ដំណាក់កាលចុះលេខសម្ងាត់ ធ្វើកំណែ ស្រង់ពិន្ទុ និងប្រកាសផ្សាយលទ្ធផលបណ្ដោះអាសន្ន ៖

១-ក្រុមការងារចុះលេខសម្ងាត់ត្រូវ ៖

- ផ្ដល់លេខសម្ងាត់លើសន្លឹកកិច្ចការរបស់បេក្ខជន
- កាត់ផ្ដាច់ក្បាលសន្លឹកកិច្ចការ និងរក្សាសន្លឹកកិច្ចការទុកជូនក្រុមការងារកំណែ
- ទទួល និងតភ្ជាប់លេខសម្ងាត់សន្លឹកកិច្ចការកំណែរួច
- ពិនិត្យភាពត្រឹមត្រូវ នៃសន្លឹកកិច្ចការរបស់បេក្ខជនទាំងមូល ។ ក្នុងករណីរកឃើញភាពមិនប្រក្រតីណាមួយនៅលើសន្លឹកកិច្ចការដូចជា សញ្ញាសម្គាល់ ឬមិនបានបំពេញត្រឹមត្រូវនៅលើក្បាលសន្លឹកកិច្ចការត្រូវដកហូតសន្លឹកកិច្ចការនោះទុកដោយឡែក ហើយត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដើម្បីសុំការសម្រេចពីប្រធានគណៈកម្មការកណ្ដាល ។

២-ក្រុមការងារកំណែត្រូវ ៖

- ធ្វើកំណែលើសន្លឹកកិច្ចការរបស់បេក្ខជន ។ រាល់កំណែសន្លឹកកិច្ចការរបស់បេក្ខជន និងការផ្ដល់ពិន្ទុត្រូវផ្ទៀងផ្ទាត់ជាមួយគំរូចម្លើយរបស់វិញ្ញាសានីមួយៗ ដែលគណៈកម្មការកណ្ដាលរៀបចំការប្រឡងបានកំណត់
- ប្រគល់សន្លឹកកិច្ចការទាំងអស់ឲ្យទៅក្រុមចុះលេខសម្ងាត់ បន្ទាប់ពីបានផ្ដល់ពិន្ទុចប់សព្វគ្រប់ ។

៣-ក្រុមការងារត្រួតពិនិត្យកំណែ ៖

- ត្រួតពិនិត្យក្រុមការងារកំណែ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃកំណែ
- ក្នុងករណីពិនិត្យឃើញភាពពុំប្រក្រតីលើកំណែ ត្រូវសាកសួរ និងធ្វើរបាយការណ៍ ។

៤-ក្រុមការងារស្រង់ពិន្ទុត្រូវ ៖

- សម្រង់ពិន្ទុរបស់បេក្ខជនពីខ្ពស់មកទាប
- ធ្វើបញ្ជីសម្រង់ពិន្ទុ ដើម្បីជូនគណៈកម្មការកណ្ដាលពិនិត្យ សម្រេច ។

ក្រោយពីបញ្ចប់នីតិវិធី នៃការចុះលេខ កំណែ និងស្រង់ពិន្ទុ ត្រូវផ្សព្វផ្សាយអំពីលទ្ធផលបណ្ដោះអាសន្ននៃការប្រឡងប្រជែងជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិនៅតាមមណ្ឌលប្រឡង ដោយគណៈកម្មការកណ្ដាលរៀបចំការប្រឡងប្រជែងជ្រើសរើស ។

ដំណើរការប្រឡងប្រជែងជ្រើសរើសចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ មានរយៈពេលចំនួន០៣ខែ ១៥ថ្ងៃ គិតចាប់ពីថ្ងៃផ្សព្វផ្សាយ ដល់ថ្ងៃប្រកាសលទ្ធផល ។

ទទួលបានសេចក្ដីណែនាំនេះ ស្នើឯកឧត្ដម អស់លោកប្រធានអនុគណៈកម្មការ និងក្រុមការងារទាំងអស់ត្រូវផ្សព្វផ្សាយអនុវត្ត ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាព ហើយរាយការណ៍អំពីលទ្ធផលមកគណៈកម្មការកណ្ដាលរៀបចំការប្រឡងប្រជែងជ្រើសរើស ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១៦

**រដ្ឋលេខាធិការ**

**និងជាប្រធានគណៈកម្មការកណ្ដាល**

**នាយឧត្ដមសេនីយ៍ ឯម_សំអាន**